**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គនាយកដ្ឋានពន្ធដារ**

លេខ......៦៣៥......អពដ

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិនា ឆ្នាំ ២០១៤

# សេចក្ដីជូនដំណឹង
## ស្ដីពីភាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ

អនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្ដីពីសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសជម្រាបជូន លោកឧកញ៉ា លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស(របបពិត)ឱ្យបានជ្រាបថា អ្នកជាប់ពន្ធទាំងអស់ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ ដែលក្នុងនោះត្រូវប្រកាសអំពីចំណូល-ចំណាយក្នុងការប្រកបអាជីវកម្មឱ្យបានស្មោះត្រង់ និងត្រូវបង់ប្រាក់ពន្ធទាំងនោះឱ្យបានត្រឹមត្រូវទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលបានកំណត់។

ក្រៅពីកាតព្វកិច្ចខាងលើ អ្នកជាប់ពន្ធទាំងអស់ត្រូវមានកាតព្វកិច្ចជាភ្នាក់ងារកាត់ទុកនិងបង់ជាប្រាក់ពន្ធពីការបើកប្រាក់នានាដូចមានចែងក្នុងមាត្រា២៣ មាត្រា២៥ មាត្រា២៦ និងមាត្រា៥២ នៃច្បាប់ស្ដីពីសារពើពន្ធ និងត្រូវកាន់កត់ត្រាបញ្ជិកាគណនេយ្យនិងឯកសារនានាទៅតាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ ព្រមទាំងត្រូវចេញវិក្កយបត្រដែលមាននិទ្ទេសត្រឹមត្រូវលើរាល់ការងារជំនួញ។

ប្រសិនបើអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាស ណាមួយដឹងឮឬមានចេតនាធ្វើឱ្យសហគ្រាសមិនប្រកាស ឬប្រកាសបន្ថយប្រាក់ពន្ធត្រូវបង់ ឬមិនឱ្យបង់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ អភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករទាំងនោះត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធដែលត្រូវបង់។

អគ្គនាយកដ្ឋានពន្ធដារមានកាតព្វកិច្ចនិងអំណាចក្នុងការចុះធ្វើសវនកម្ម ត្រួតពិនិត្យភាពត្រឹមត្រូវនៃការប្រកាស និងការអនុវត្តកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ។ ក្នុងករណីដែលអ្នកជាប់ពន្ធមានការធ្វេសប្រហែស ធ្វេសប្រហែសធ្ងន់ធ្ងរ ឬបានប្រព្រឹត្តអំពើរាំងស្ទះឬបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ អ្នកជាប់ពន្ធនឹងត្រូវទទួលរងទោសទណ្ឌខាងរដ្ឋបាល ព្រមទាំងទោសទណ្ឌផ្នែកព្រហ្មទណ្ឌដូចមានចែងក្នុងច្បាប់ស្ដីពីសារពើពន្ធ។ បន្ថែមពីលើនេះ អគ្គនាយកដ្ឋានពន្ធដារនឹងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារដូចមានចែងក្នុងមាត្រា១០៩ដល់មាត្រា១១៥ នៃច្បាប់ស្ដីពីសារពើពន្ធ ក្នុងនោះមានការបញ្ឈប់ការនាំចេញ-នាំចូល ការឃាត់ទុកគណនីធនាគារ ការបិទអាជីវកម្ម ការស្នើសុំឱ្យអាជ្ញាធរមានសមត្ថកិច្ចដកហូតអាជ្ញាប័ណ្ណអាជីវកម្ម ព្រមទាំងការប្ដឹងទៅតុលាការចោទប្រកាន់ពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ ជាដើម។

អាស្រ័យហេតុនេះ សូមលោកឧកញ៉ា លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស មេត្តាជ្រាបជាព័ត៌មាននិងរួមសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការប្រមូលចំណូលពន្ធជូនរដ្ឋ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋាន
ពន្ធដារ

**គង់ វិបុល**

**ចម្លងជូន:**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៥៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh